# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
# គម្រោងបញ្ចប់ផែនការ
# កំណែលើកទី ២៣
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩


**សេចក្តីសង្ខេប** ........ 2
I. **សេចក្តីផ្តើម** ........ 3
II. **វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស** ........ 7
III. **ផែនការបញ្ចប់ការស៊ើបអង្កេត** ........ 8
ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត ........ 8
ខ. អង្គបុរេជំនុំជម្រះ ........ 8
IV. **ផែនការបញ្ចប់សវនាការ** ........ 10
ក. សំណុំរឿង០០២/០២ ........ 10
ខ. សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ ........ 10
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** ........ 11
ក. សំណុំរឿង០០២/០២ ........ 11
ខ. សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤ ........ 11
VI. **សេចក្តីសន្និដ្ឋាន** ........ 12
ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។


**សម្គាល់៖**
គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។" ហេតុដូច្នេះពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំ និងចេញដោយការិយាល័យរដ្ឋបាលដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) ត្រូវបានរៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ១៧ នៃគម្រោងបញ្ចប់ផែនការនេះ ដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

នៅក្នុងអំឡុងត្រីមាសនេះ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០២ បានបើកសវនាការចំនួនបីថ្ងៃលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ និងបានទទួលសារណាបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បំភ្លឺអំពីផលវិបាកផ្លូវច្បាប់នៃមរណភាពរបស់ នួន ជា នៅដំណាក់កាលកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២។ ជាចុងក្រោយ បន្ទាប់ពី ខៀវ សំផន បានដាក់ញត្តិប្តឹងជំទាស់ចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូល គណៈកម្មាធិការរដ្ឋបាលតុលាការបានជ្រើសរើសចៅក្រម ដើម្បីជំនួសចៅក្រមដែលបានកំណត់អត្តសញ្ញាណក្នុងបណ្តឹងនោះ ដើម្បីធ្វើការវិនិច្ឆ័យបញ្ហាបណ្តឹងជំទាស់នេះ។

# I. សេចក្ដីផ្ដើម

1 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្ដើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្ដី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែ មេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។

2 គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី២៣ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

3 ឯកសារនេះផ្តោតជាពិសេសលើការវិវត្តនាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក. និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេ បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[2]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក. ត្រូវចាត់ការតាមនីតិវិធី។

4 សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ (ហៅ *ឌុច*) គឺជាសំណុំរឿងដំបូងដែលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក. ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

5 អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួន២ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមសាលាដំបូងដែលផ្តន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។

6 ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម សហករណ៍ត្រាំកក់ (រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹទ្ធលើពុទ្ធសាសនិក) ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ភ្នំក្រោល និងស-២១ ការបោសសម្អាតផ្ទៃក្នុង និងបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ សវនាការលើអង្គហេតុបានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបផ្ទាល់មាត់អំពីការយល់ឃើញ និងផ្នែកសម្រេចសេចក្តីនៃសាលក្រមនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងបានចេញសាលក្រមជាលាយលក្ខណ៍អក្សររបស់ខ្លួនជាបីភាសាផ្លូវការរបស់តុលាការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះសន្និដ្ឋានថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានផ្តន្ទាទោសពួកគេម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត[3]។ បន្ទាប់ពីបានចុះកំណត់ហេតុសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន រួចមក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះតុលាការកំពូល។

7 នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា ទទួលមរណភាពក្នុងអាយុ៩៣ឆ្នាំ ខណៈដែលទទួលព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខប្រឆាំងនឹង នួន ជា នៅថ្ងៃទី១៣ ខែសីហា ប៉ុន្តែបានសម្រេចថានៅតែទទួលសំណើរបស់មេធាវីការពារក្តីក្នុងការបំភ្លឺបញ្ជាក់អំពីវិបាកផ្លូវច្បាប់កើតចេញពីមរណភាពរបស់គាត់នៅក្នុងដំណាក់កាលកិច្ចនីតិវិធីនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានដាក់សេចក្តីបំភ្លឺរបស់ខ្លួននៅថ្ងៃទី២២ ខែវិច្ឆិកា ដែលសម្រេច *ក្នុងចំណោមរឿងផ្សេងទៀត* ថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹង នួន ជា មិនត្រូវបានមោឃភាពក្រោយមរណភាពរបស់គាត់ឡើយ និងបានបញ្ជាក់ថា ផ្ទុយទៅនឹងការសន្និដ្ឋានរបស់មេធាវីការពារក្តី ពុំមានកិច្ចដំណើរការនីតិវិធីបន្តទៀតអាចធ្វើទៅបាននៅក្នុងរឿងក្តីប្រឆាំងនឹង នួន ជា នោះទេ។

8 នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែលមិនមាន

---

[3] សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក./អ.ជ.ស.ដ. ([www.eccc.gov.khlenldocumentlcourtlcase-00202-judgement](www.eccc.gov.khlenldocumentlcourtlcase-00202-judgement) )។

បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២ នឹងត្រូវបញ្ចប់នៅពេលសាលក្រមសំណុំរឿង០០២/០២ ចូលជាស្ថាពរ។

9 កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានផ្តួចផ្តើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងឆ្នាំ២០០៩ និងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមជាបន្តបន្ទាប់។ សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាសំណុំរឿងចំនួនបី ពោលគឺ សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ឹម ចែម សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និង សំណុំរឿងដែលនៅសេសសល់ គឺ សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។

10 នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានសម្អាងហេតុលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨[4] អង្គបុរេជំនុំជម្រះ បានសម្រេចលើបណ្តឹងឧទ្ធរណ៍លើយុត្តាធិការបុគ្គល ដោយបានបិទបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងនេះ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើ អ៊ឹម ចែម ចាត់ទុកជាបានការដែលជាការបញ្ចប់ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿងនេះ។

11 ដំណើរការនីតិវិធីសំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ មានវឌ្ឍនភាព ដូចខាងក្រោម៖

ក- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នា ក្នុងសំណុំរឿង០០៣ ប្រឆាំង មាស មុត ជាភាសាធ្វើការរបស់ចៅក្រមនីមួយៗ (ខ្មែរ និងអង់គ្លេស) ដែលការបកប្រែនឹងដាក់តាមក្រោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទប្រកាន់ មាស មុត ពីបទអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង បទល្មើស ក្រោមច្បាប់ជាតិ។ សហចៅក្រមស៊ើបអង្កេតជាតិបានទម្លាក់ការចោទប្រកាន់ដោយមូលហេតុពុំមានយុត្តាធិការបុគ្គល។ ដីកាសំណោះស្រាយទាំងពីរមានអមដោយសេចក្តីសម្រេចលើពាក្យសុំរបស់ដើមបណ្តឹង រដ្ឋប្បវេណី។ សំណៅបកប្រែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិជាភាសាអង់គ្លេស នៅក្នុងសំណុំរឿងនេះ ត្រូវបានជូនដំណឹងនៅថ្ងៃទី០១ ខែកុម្ភៈ ចំណែកសំណៅបកប្រែដីកាដំណោះស្រាយជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩។ បណ្តឹងឧទ្ធរណ៍ចំនួនបីត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ។ មេធាវីការពារក្តី និង សហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ។ ចម្លើយតប និងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវបានដាក់ដោយភាគី ជាភាសាអង់គ្លេស និងភាសាខ្មែរ នៅចុងត្រីមាសទី៣ ឆ្នាំ២០១៩។ នៅថ្ងៃទី២៧ ដល់២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបើកសវនាការរយៈពេលបីថ្ងៃលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ អង្គបុរេជំនុំជម្រះបានព្យាករថានឹងអាចចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅត្រឹមត្រីមាសទី២ ក្នុងឆ្នាំ២០២០។

ខ- នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នាក្នុងសំណុំរឿង០០៤/០២ ប្រឆាំងនឹង អោ អាន ជាភាសាដែលចៅក្រមធ្វើការ (ភាសាខ្មែរ និងភាសាអង់គ្លេស) ហើយការបកប្រែនឹងដាក់ជូនតាមក្រោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចចោទប្រកាន់ អោ អាន ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង បទល្មើសតាមច្បាប់ជាតិមួយចំនួនទៀត។ សហចៅក្រមស៊ើបអង្កេតជាតិបានទម្លាក់ការចោទប្រកាន់ដោយហេតុពុំមានយុត្តាធិការបុគ្គល។ ដីកាដំណោះស្រាយមានអមដោយសេចក្តីសម្រេចលើសំណើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សំណៅបកប្រែជាភាសាខ្មែរនិងអង់គ្លេសនៃដីកាដំណោះ

[4] កំណែប្រែទី១៧ ដល់ ២២ នៃគម្រោងបញ្ចប់ផែនការ ដែលពីមុនដាក់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ថាជាកាលបរិច្ឆេទចេញ។

ស្រាយត្រូវបានជូនដំណឹង នៅថ្ងៃទី៣០ ខែតុលា និងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៨។ បណ្តឹងឧទ្ធរណ៍ចំនួន ០៣ ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ៖ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ។ អង្គបុរេជំនុំជម្រះបានធ្វើសវនាការចំនួន ០៣ថ្ងៃ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងខែមិថុនា ឆ្នាំ២០១៩។ នៅថ្ងៃទី១៩ ខែធ្នូ អង្គបុរេជំនុំជម្រះបានដាក់សេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយប្រកាសជាឯកច្ឆន្ទថា "ការចេញដីកាដំណោះស្រាយពីផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតគឺខុសច្បាប់"។ ដោយសារតែអង្គបុរេ "មិនអាចទទួលបានសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅសេចក្តីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីឡើយ" ចៅក្រមបានភ្ជាប់មតិយោបល់របស់ខ្លួនទៅនឹងសេចក្តីពិចារណាជាឯកច្ឆន្ទនេះ។ អង្គបុរេជំនុំជម្រះនៅតែបានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីដែលសេចក្តីសម្រេចរបស់អង្គបុរេគ្រោងចេញនៅត្រឹមត្រីមាសទី២ ក្នុងឆ្នាំ២០២០។

គ- នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរផ្សេងគ្នាក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ ជាភាសាការងាររបស់ចៅក្រមនីមួយៗ (ភាសាខ្មែរ និង អង់គ្លេស) ដោយដាក់សំណៅបកប្រែពេលក្រោយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចចោទប្រកាន់ យឹម ទិត្យ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសតាមច្បាប់ជាតិ។ សហចៅក្រមស៊ើបអង្កេតជាតិសម្រេចលើកលែងចោទប្រកាន់ ដោយមូលហេតុពុំមានយុត្តាធិការបុគ្គល។ ដីកាដំណោះស្រាយមានអមដោយសេចក្តីសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សំណៅបកប្រែជាភាសាខ្មែរនៃដីកាដំណោះស្រាយត្រូវបានជូនដំណឹង នៅថ្ងៃទី១៤ ខែសីហា ចំណែកឯភាសាអង់គ្លេស នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។ បណ្តឹងឧទ្ធរណ៍ចំនួនប្រាំបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ៖ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិ និងដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ហើយមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍បន្ថែមទៀត ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរផ្សេងគ្នា។ អង្គបុរេជំនុំជម្រះបានព្យាករណ៍ថានឹងចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅត្រឹមត្រីមាសទី៤ ក្នុងឆ្នាំ២០២០។

12 ផ្អែកលើការវិវត្តក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការកំណត់ព្រឹត្តិការណ៍សំខាន់ចំនួនបួនសម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់ចំនួនពីរនៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ដែលពាក់ព័ន្ធគឺ៖

(i) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខដែលនៅសេសសល់ ប្រឆាំងនឹងសាលក្រម (ត្រីមាសទី១ ឆ្នាំ២០២០) និង

(ii) ការចេញសាលដីកាក្នុងភាសាធ្វើការទាំងបី (ត្រីមាសទី៤ ឆ្នាំ២០២២)។

13 នៅក្នុងសំណុំរឿង០០៣ សំណុំរឿង០០៤ ព្រឹត្តិការណ៍ដ៏សំខាន់សរុបចំនួន០២ ត្រូវបានកំណត់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរ។ ក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានរកឃើញថាទុកជាបានការ នឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ" និង

បណ្តឹងសាទុក្ខ[5]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរដែលបន្តនៅសេសសល់ គឺ៖

(iii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី២ ឆ្នាំ២០២០)។ និង

(iv) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០២០)។

## II. វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស

14 ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខាន ដោយភាពមិននឹងនរផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឱ្យបុគ្គលិកជាតិធ្វើកូដកម្មមិនធ្វើការចំនួនពីរលើក ក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់ មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-២០១៩ សម្រាប់ភាគីអន្តរជាតិនៃ អ.វ.ត.ក. គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឱ្យមានស្ថិរភាពដល់ស្ថានភាពថវិកា និងធ្វើឱ្យមានការផ្តោតមូលទៅលើការធ្វើឱ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់ បាននាំឱ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងអំឡុងពាក់កណ្តាល ឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

15 ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិក្នុងលក្ខណៈជាវិធានការពិសេស បានអនុញ្ញាតឱ្យអគ្គលេខាធិការសម្រេច កំណត់ទឹកប្រាក់ចំនួនមិនលើសពី ៧,៥ លានដុល្លារ នៅខែធ្នូ ឆ្នាំ២០១៨ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក. សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅ អ.វ.ត.ក. មិនឱ្យរអាក់រអួលក្នុងកំឡុង៧ខែដំបូងនៃឆ្នាំ២០១៩ ដោយបើកឱកាសឱ្យមានការរៃអង្គាសថវិកា ស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់វិភាគទានដោយផ្ទាល់ចំនួន ៣,៩ លានដុល្លារដូចដែលបានធ្វើនៅក្នុងឆ្នាំ២០១៨ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ០៦ ខែដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០១៩ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃ អ.វ.ត.ក.។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថា ទំហំការងារបច្ចុប្បន្នរបស់ អ.វ.ត.ក. បានបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ច។ វិភាគទានស្ម័គ្រចិត្តសម្រាប់ឆ្នាំ២០១៩ គឺមានចំនួន ៦,២ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ ខណៈដែលភាគីជាតិបានទទួលវិភាគទានពីម្ចាស់ជំនួយអន្តរជាតិ ចំនួន១លាន ដុល្លារបន្ថែមទៀត។ ប្រការនេះធៀបទៅនឹងថវិកា ដែលបានអនុម័តចំនួន ១៦,០១ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ៥,៣៧ លានដុល្លារសម្រាប់ភាគីជាតិ។

16 នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. បានអនុម័តវិសោធនកម្មទៅលើវិធាននៃផ្ទៃក្នុងដែលអនុញ្ញាតឱ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរ ដរាបណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឱ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់[6]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ

[5] ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

[6] វិធាន៦៦*ស្ទួន*។

ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាច កាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីមួយដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមាន ចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជំម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[7]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់ កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ០០២/០២។

17 ការិយាល័យរដ្ឋបាលបានរក្សាសេវាកម្មរបស់បុគ្គលិកឯកទេសភាសាបន្ថែមទៀតដើម្បីគាំទ្រដល់ការិយាល័យតុលាការដើម្បីធានាសេវាបកប្រែនិងប្រតិចារឹកបានទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

18 ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) អង្គបុរេជំនុំជម្រះ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

19 កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានផ្តួចផ្តើមឡើងក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងឆ្នាំ២០០៩ ហើយនឹងក្រោយពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាសំណុំរឿងចំនួនបីដោយឡែកពីគ្នា ពោលគឺ សំណុំរឿង ០០៤/០១ ពាក់ព័ន្ធនឹង អ៊ុំ ចែម សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និងសំណុំរឿង០០៤ ដែលនៅសល់ គឺសំណុំរឿងប្រឆាំង យឹម ទិត្យ។

### ក. *ការិយាល័យសហចៅក្រមស៊ើបអង្កេត*

20 នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេតបានចុះសេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍ចុងក្រោយនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនបួនក្នុងសំណុំរឿង០០៤ និងបានបញ្ជូនសំណុំរឿងទៅអង្គបុរេជំនុំជម្រះ។ ហេតុដូច្នេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទទួលសំណុំរឿងណាមួយនៅដំណាក់កាលនេះទេ។ អាណត្តិតាមច្បាប់របស់សហចៅក្រមស៊ើបអង្កេតបញ្ចប់នៅថ្ងៃតែមួយជាមួយអាណត្តិរបស់អង្គបុរេជំនុំជម្រះ។

### ខ. *អង្គបុរេជំនុំជម្រះ*

21 ក្នុងពេលចាប់ផ្តើមត្រីមាសទី៤ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ចំនួនប្រាំបួន ពោលគឺបណ្តឹងចំនួនបួន ក្នុងសំណុំរឿង០០៣ (បណ្តឹងឧទ្ធរណ៍ចំនួនមួយ ពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និង បណ្តឹងឧទ្ធរណ៍ចំនួន៣ទៀត ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ) បណ្តឹងឧទ្ធរណ៍ចំនួនបួន ក្នុងសំណុំរឿង០០៤/០២ (បណ្តឹងឧទ្ធរណ៍ចំនួនមួយ ពាក់ព័ន្ធការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងឧទ្ធរណ៍ចំនួនបីទៀតពាក់ព័ន្ធនឹងដីកាដំណោះស្រាយ) និងបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំចំនួនមួយ ក្នុងសំណុំរឿង ០០៤។ នៅក្នុងរយៈពេលធ្វើរបាយការណ៍នេះ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចបន្ទាន់បង្ខំចំនួនបួន ក្នុងសំណុំរឿងដែលអង្គបុរេជំនុំជម្រះបានទទួល។

22 បន្ថែមលើនេះ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ទាំងបីប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០២ ដែលក្នុងសេចក្តីពិចារណានោះអង្គបុរេបានប្រកាសជាឯកច្ឆន្ទ "ថាការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់"។ ដោយសារតែអង្គបុរេ "មិនអាចទទួលបានសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ ដើម្បីឈានទៅសេចក្តីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីឡើយ" ចៅក្រមបានភ្ជាប់មតិយោបល់របស់ខ្លួនទៅនឹងសេចក្តីពិចារណាជាឯកច្ឆន្ទនេះ។ ចៅក្រមជាតិបានតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេត

[7] វិធាន៨៩*ស្ទួន៣*។

ជាតិ ចំណែកចៅក្រមអន្តរជាតិឯកភាព “ថា អោ អាន ត្រូវបញ្ជូនទៅជំនុំជម្រះ ដូចដែលមានចែងក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដូចដែលៗ...បានកែប្រែ” តាមយោបល់របស់ពួកគេ។ អង្គបុរេជំនុំជម្រះនៅតែទទួលបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនគ្រោងចេញសេចក្តីសម្រេចនៅត្រីមាសទីពីរ ឆ្នាំ២០២០។

23 នៅថ្ងៃទី២៧, ២៨ និង ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានបើសវនាការចំនួនបីថ្ងៃលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣។ អង្គបុរេបានចេញរបាយការណ៍សាធារណៈអំពីរឿងក្តី ដែលបង្ហាញពីអង្គហេតុពាក់ព័ន្ធ និងប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៣ ក៏ដូចជាព័ត៌មានលម្អិតអំពីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខខ្លួន។

24 អង្គបុរេជំនុំជម្រះមានបំណងចេញសេចក្តីសម្រេចលើដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង សំណុំរឿង ០០៤ ក្នុងពេលវេលាសមស្រប អាស្រ័យលើលក្ខណៈនៃសេចក្តីសន្និដ្ឋាន និងការដាក់បណ្តឹងឧទ្ធរណ៍មួយចំនួនដែលអាចមាន ដែលបច្ចុប្បន្ននេះត្រូវបានប៉ាន់ស្មានថានៅរយៈពេលពីរត្រីមាស ក្រោយពីទទួលបានសារណាពេញលេញលើបណ្តឹងឧទ្ធរណ៍។ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេនឹងត្រូវការពេលវេលាប្រមាណមួយត្រីមាស ក្រោយពេលចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយលើដីកាដំណោះស្រាយ ដើម្បីសម្រេចលើបណ្តឹងទាំងអស់នោះ។

25 ដើម្បីទទួលបានសេចក្តីសន្និដ្ឋានពេញលេញអំពីបណ្តឹងឧទ្ធរណ៍ សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានទាំងនោះ និងការឆ្លើយតបទៅនឹងចម្លើយតបទាំងនោះ ត្រូវដាក់ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬបារាំង។ ការចេញដីកាដំណោះស្រាយចំនួនពីរផ្សេងគ្នា និងផ្ទុយគ្នាក្នុងសំណុំរឿង០០៣, ០០៤ និង ០០៤/០២ ដែលពុំធ្លាប់មានពីមុនមក និងការចេញដីកាដំណោះស្រាយជាភាសារបស់សហចៅក្រមរៀងៗខ្លួន គឺពិតជាត្រូវការពេលវេលាបន្ថែមសម្រាប់ធ្វើសារណាលើបណ្តឹងឧទ្ធរណ៍ឲ្យបានពេញលេញ។

26 គិតត្រឹមត្រីមាសទីបួន ចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះដែលកំពុងបំពេញការងារ រួមទាំងចៅក្រមបម្រុងអន្តរជាតិ កំពុងចាត់ការលើដំណើរការបណ្តឹងដិតចិត្តអនុលោមតាមវិធាន ៣៤(៦) នៅក្នុងសំណុំរឿង ០០២/០២។ ជាលទ្ធផល និង ក្នុងលក្ខខណ្ឌអង្គបុរេជំនុំជម្រះមានបុគ្គលិកគ្រប់គ្រាន់ និងការបកប្រែបានលឿនលើសេចក្តីសន្និដ្ឋានរបស់ភាគី និងសេចក្តីសម្រេចតុលាការជាបីភាសាធ្វើការទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញ ការប៉ាន់ស្មាននាពេលបច្ចុប្បន្នមានដូចខាងក្រោម៖

ក. ក្នុង*សំណុំរឿង០០៤/០២* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចនឹងរំពឹងទុកថានឹងចេញនៅត្រឹមត្រីមាសទីពីរ ឆ្នាំ២០២០។

ខ. ក្នុង*សំណុំរឿង ០០៣* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវបានផ្តល់សារណាពេញលេញនៅត្រឹមថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩។ ការប៉ាន់ស្មានបច្ចុប្បន្នសម្រាប់ការបញ្ចប់សំណុំរឿង ០០៣ គឺនឹងមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចេញនៅត្រឹមត្រីមាសទីពីរ ឆ្នាំ២០២០។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមអន្តរជាតិ លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចនឹងរំពឹងទុកត្រឹមត្រីមាសទីបី ឆ្នាំ២០២០។

គ ក្នុង*សំណុំរឿង ០០៤* ការបកប្រែដីកាដំណោះស្រាយខ្វែងគ្នាត្រូវបានដាក់នៅត្រឹមថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។ បណ្តឹងឧទ្ធរណ៍ចំនួនប្រាំប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានដាក់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ដែលអាចនឹងត្រូវបានធ្វើសារណាពេញលេញនៅត្រីមាសទីពីរ ឆ្នាំ២០២០។ ការគ្រោងទុកបច្ចុប្បន្នគឺថានឹងមានសាលដីកា លើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ អាស្រ័យលើភាពស្មុគស្មាញ និងទំហំនៃបណ្តឹងឧទ្ធរណ៍ ត្រឹមត្រីមាសទីបួន

ឆ្នាំ២០២០។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាសម្រេច លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចរំពឹងថាចេញនៅត្រីមាសទី១ ឆ្នាំ២០២១។

## IV. ផែនការបញ្ចប់សវនាការ

### ក. *សំណុំរឿង០០២/០២*

27 កិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយពីពេលសវនាការអស់ចំនួន២៧៤ថ្ងៃ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីសរុបចំនួន១១៤ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៦៣នាក់ និង អ្នកជំនាញចំនួន ៨នាក់ ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មចំនួន០៨ បទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការប្រព្រឹត្តលើពុទ្ធសាសនិក ជនជាតិចាម និង ជនជាតិវៀតណាម។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមដោយផ្ទាល់មាត់នៅក្នុងសំណុំរឿង ០០២/០២ រួមជាមួយសេចក្តីសង្ខេបនៃការរកឃើញ និងបានជូនដំណឹងអំពីសាលក្រមជាបីភាសាផ្លូវការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមជនជាតិពិន្ទ ក្រុមជាតិសាសន៍ និងក្រុមពូជសាសន៍វៀតណាម។ អង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោស នួន ជា បន្ថែមទៀតពីបទប្រល័យពូជសាសន៍លើជាតិពន្ធចាម និងក្រុមសាសនាចាម ក្រោមទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។ ទាំង នួន ជា ទាំង ខៀវ សំផន ត្រូវបានស្រេចឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះបានពិចារណាទោសជាប់ពន្ធនាគារអស់មួយជីវិតដែលបានកំណត់លើ នួន ជា និង ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១ ហើយបានស្របទោសនៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ ជាទោសជាប់ពន្ធនាគារអស់មួយជីវិតតែមួយ។

28 នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចុះសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន និងបានបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះតុលាការកំពូល។

### ខ. *សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤*

29 កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមក្រោយពីដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងឆ្នាំ២០០៩។ បន្ទាប់មក សំណុំរឿង០០៤ ត្រូវបានបំបែកជាបីសំណុំរឿងផ្សេងគ្នា ក្នុងនោះ សំណុំរឿងចំនួន ២ នៅដំណើរការនៅឡើយគឺ៖ សំណុំរឿង០០៤/២ ពាក់ព័ន្ធនឹង អោ អាន និង សំណុំរឿង០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ ។

30 នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២។ គិតត្រឹមចុងត្រីមាសនេះ អង្គជំនុំជម្រះសាលាដំបូង បានទទួលឯកសារពីភាគីក្នុងសំណុំរឿងនេះ។

31 រហូតដល់មានសេចក្តីសម្រេចចុងក្រោយថាតើសំណុំរឿងទាំងអស់ ឬណាមួយនៃសំណុំរឿង ០០៣ សំណុំរឿង ០០៤/០២ និងសំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចមានការប៉ាន់ប្រមាណលើពេលវេលាដែលត្រូវការដើម្បីបញ្ចប់សវនាការទាំងនេះ។ ការវាយតម្លៃទៅលើពេលវេលា ដែលត្រូវការអាចនឹងពឹងផ្អែកលើចំនួនចុងចោទ និងភាពស្មុគស្មាញផ្អែកអង្គច្បាប់ និងអង្គហេតុនៃបទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្ដឹងសាទុក្ខ

### ក. *សំណុំរឿង០០២/០២*

32 នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានទទួលមរណភាព ក្នុងអាយុ៩៣ឆ្នាំ ខណៈដែលកំពុងទទួលព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចនីតិវិធីបណ្ដឹងសាទុក្ខលើ នួន ជា នៅថ្ងៃទី១៣ ខែសីហា ហើយនៅថ្ងៃទី២២ ខែវិច្ឆិកាបានចេញការបញ្ជាក់បំភ្លឺលើវិបាកគតិយុត្តកើតចេញពីមរណភាពរបស់ នួន ជា នៅក្នុងដំណាក់កាលនីតិវិធីនេះ[8]។

33 នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមជំនុំជម្រះ ដោយមានមូលដ្ឋានតែមួយប៉ុណ្ណោះ។ ដោយពិចារណាលើទំហំ កម្រិត និងភាពស្មុគស្មាញនៃកិច្ចនីតិវិធីរបស់សំណុំរឿង០០២/០២ និងបញ្ហាផ្លូវច្បាប់ និង/ឬអង្គហេតុដែលបង្ហាញដោយមេធាវីការពារក្ដី ខៀវ សំផន នៅក្នុងសេចក្ដីជូនដំណឹងបណ្ដឹងសាទុក្ខ[9] អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតរយៈពេល១៨០ថ្ងៃបន្ថែមក្នុងការដាក់បណ្ដឹងសាទុក្ខ[10]។ អង្គជំនុំជម្រះបានណែនាំថា ចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល១២០ថ្ងៃក្រោយពីការជូនដំណឹង ជាមួយភាសា និងបានជូនដំណឹងដល់ភាគីថា ការឆ្លើយតបទៅនឹងចម្លើយតបនឹងត្រូវបើកសវនាការផ្ទាល់មាត់ដែលគ្រោង នឹងធ្វើឡើងនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១។

34 នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ មេធាវីការពារក្ដី ខៀវ សំផន បានដាក់បណ្ដឹងជិតចិត្តចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលចំនួន ០៦ រូប ដោយផ្អែកលើមូលដ្ឋាននៃការសម្រេចលើបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១។ អនុលោមតាមវិធាន ៣៤(៦) នៃវិធានផ្ទៃក្នុង គណៈកម្មាធិការរដ្ឋបាលតុលាការបានជ្រើសរើសចៅក្រមពេញសិទ្ធិនៃអង្គបុរេជំនុំជម្រះ ចំនួន ០៥ រូប និងចៅក្រមអន្តរជាតិបម្រុងនៃអង្គបុរេជំនុំជម្រះចំនួន ០១ រូប យកមកជំនួសចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវបានប្ដឹង ដើម្បីពិចារណាលើបណ្ដឹងជិតចិត្ត។

35 អង្គជំនុំជម្រះតុលាការកំពូលរំពឹងថាសាលដីកានឹងត្រូវចេញទាំងបីភាសាផ្លូវការ នៅត្រឹមត្រីមាសទី៤ ឆ្នាំ២០២២។ ការព្យាករណ៍នេះគឺអាស្រ័យលើភាពបន្ទាន់នៃដំណើរការបណ្ដឹងសាទុក្ខ រួមទាំងលទ្ធផលនៃបណ្ដឹងជិតចិត្ត និងកត្តាពាក់ព័ន្ធនានា ដូចជា អង្គជំនុំជម្រះមានបុគ្គលិកគ្រប់គ្រាន់ សុខភាព និងសម្បទារបស់ជនជាប់ចោទ និងសេវាបកប្រែឯកសារទាន់ពេលវេលា នឹងត្រឹមត្រូវ។

### ខ. *សំណុំរឿង០០៣ សំណុំរឿង០០៤/០២ និង សំណុំរឿង០០៤*

36 ប្រសិនបើសំណុំរឿង០០៣ សំណុំរឿង០០៤/០២ និងសំណុំរឿង០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្ដឹងសាទុក្ខភ្លាមៗ ឬបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចកើតឡើង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជា

---

[8] អង្គជំនុំជម្រះតុលាការកំពូលបានបំភ្លឺថា៖ ការបញ្ចប់កិច្ចដំណើរការនីតិវិធីមិនបានមោឃភាពការសន្និដ្ឋាននៅក្នុងសាលក្រមទាក់ទងនឹង នួន ជា ឡើយ និងមានតម្លៃស្មើទៅនឹងការសន្និដ្ឋានក្រោយមរណភាពថាគ្មានពិរុទ្ធនោះទេ។ សាលដីកាស្ដាពរលើពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ នួន ជា មិនអាចធ្វើទៅបាន ដោយសារមរណភាពរបស់គាត់បានរារាំងមិនឱ្យមានការពិនិត្យលើបណ្ដឹងសាទុក្ខ ហើយមរណភាពរបស់ នួន ជា មិនប៉ះពាល់ការផ្ដល់សំណងទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ។

[9] មេធាវីការពារក្ដីបានបង្ហាញកំហុសអង្គច្បាប់ និង/ឬអង្គហេតុចំនួនប្រមាណ១៨២៤ចំណុច នៅក្នុងសាលក្រមជំនុំជម្រះ និង សេចក្ដីសម្រេចចំនួន៣៥៥ ផ្សេងទៀត (១៥៩ ផ្ទាល់មាត់ និង ១៩៦ លាយលក្ខណ៍អក្សរ) របស់អង្គជំនុំជម្រះសាលាដំបូង។

[10] វិធាន១០៧(៤)នៃវិធានផ្ទៃក្នុងចែងថា សារណាបណ្ដឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការប្ដឹងសាទុក្ខ។ កាលកំណត់ដាក់សារណាបណ្ដឹងសាទុក្ខគឺចាប់ពីឥឡូវទៅ ឬត្រឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ជាមួយភាសាប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់បន្ថែមនូវការបន្ថែមចំនួនទំព័រតាមការណែនាំអនុវត្ត ពី៦០ទំព័រដល់៧៥០ទំព័រ។

ឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវ ក្នុងការសម្រេចលើបណ្តឹងសាទុក្ខណាមួយនៃសំណុំរឿងពាក់ព័ន្ធ។

## VI. **សេចក្តីសន្និដ្ឋាន**

37 យើងបានសម្រេចបានព្រឹត្តិការណ៍សំខាន់មួយ ក្នុងអំឡុងពេលត្រីមាសនេះ ដោយមានការចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ ដោយអង្គបុរេជំនុំជម្រះ។

38 សម្រាប់*ឆ្នាំ២០២០* យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់បី គឺ (i) ការដាក់សារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ (ii) ការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ប្រឆាំង មាស មុត ថាតើត្រូវបញ្ជូនរឿងក្តីទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី និង (iii) ការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូន ទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី។

39 សម្រាប់*ឆ្នាំ២០២២* ព្រឹត្តិការណ៍សំខាន់មួយត្រូវបានរំពឹងទុកគឺ (iv) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល។

40 ក្នុងករណីដែលសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង ០០៤/០២ ត្រូវបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករនៅពេលនោះ។

41 ព្រឹត្តិការណ៍សំខាន់ៗដែលបានព្យាករមានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី២៣ - ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| សំណុំរឿង | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ២០២១ | | | | ២០២២ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| សំណុំរឿង០០២/០១ | ដំណាក់កាលជំនុំជម្រះ | (ក) | | | | | | (ខ) | (គ) | បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម | | | (ឃ) | | | | | | | | | | | (ង) |
| សំណុំរឿង ០០៣ មាស មុត | កិច្ចស៊ើបសួរតាមផ្លូវតុលាការ | | | | | | | (ច) | (ឆ) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ | | | | | (ជ) | | | | | | | | | |
| សំណុំរឿង ០០៤/០២ អោ អាន | កិច្ចស៊ើបសួរតាមផ្លូវតុលាការ | | | | | | (ច) | (ឆ) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ | | | (ជ) | | | | | | | | | | | | |
| សំណុំរឿង ០០៤ យឹម ទិត្យ | កិច្ចស៊ើបសួរតាមផ្លូវតុលាការ | | | | | | | | | (ច) | (ឆ) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ | | | | (ជ) | | | | | | | | |

(ក) សេចក្ដីថ្លែងបិទកិច្ចពិភាក្សាដេញដោល
(ខ) សាលក្រម៖ សង្ខេប និងផ្នែកសម្រេចសេចក្ដី
(គ) សាក្រម៖ មានសំអាងហេតុ និងជាបីភាសា
(ឃ) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម
(ង) សាលដីកា

(ច) ដីកាដំណោះស្រាយពីរផ្ទុយគ្នា តែមួយភាសាប៉ុណ្ណោះ
(ឆ) ដីកាដំណោះស្រាយពីរផ្ទុយគ្នា ជាភាសាខ្មែរ និង អង់គ្លេស
(ជ) សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ